# វគ្គបណ្តុះបណ្តាល ស្តីពី សុវត្ថិភាពឧស្សាហកម្ម

ព្រឹកថ្ងៃព្រហស្បតិ៍ ០៨កើត ខែកត្តិក ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកឧត្តម **សាត សាមី** រដ្ឋលេខាធិការតំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិត **ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម** បានអញ្ជើញជាអធិបតី ក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ស្តីពី សុវត្ថិភាពឧស្សាហកម្ម នៅសាលប្រជុំរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

វគ្គបណ្តុះបណ្តាលនេះធ្វើឡើងក្នុងគោលបំណងចែករំលែកចំណេះដឹង និងបទពិសោធន៍ ស្តីពីការគ្រប់គ្រង ការថែទាំ ការត្រួតពិនិត្យ និងផ្សព្វផ្សាយពីបទបញ្ញត្តិនានា នៃការគ្រប់គ្រងគ្រឿងចក្រគ្រឿងម៉ាស៊ីនដែលមានហានិភ័យក្នុងរោងចក្រ សិប្បកម្ម ជូនវិស័យឯកជន ជាពិសេសដល់កម្មករ អ្នកបញ្ជាឡចំហាយ អ្នកបញ្ជាគ្រឿងចក្រ គ្រឿងម៉ាស៊ីន ដែលមានហានិភ័យឲ្យបានយល់ដឹងពីការគ្រប់គ្រងសុវត្ថិភាព និងប្រសិទ្ធិភាពក្នុងការអនុវត្តន៍ការងារឲ្យបានសមស្របតាមលក្ខណៈបច្ចេកទេស ដើម្បីបញ្ចៀស និងបង្ការគ្រោះថ្នាក់ដែលអាចកើតមានឡើងនៅកន្លែងផលិតកម្ម ធ្វើឲ្យបាត់បង់អាយុជីវិតកម្មករ និងខូចខាតទ្រព្យសម្បត្តិសារធារណៈ ដើម្បីធានាឲ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព។ វគ្គបណ្តុះបណ្តាលនេះមានសិក្ខាកាមចូលរួមចំនួនសរុប ២៤០រូប មកពីរោងចក្រចំនួន៦៣ ដែលនៅរាជធានីភ្នំពេញ និងបណ្តាលខេត្តនានាដូចជា ខេត្តកណ្តាល ខេត្តបាត់ដំបង ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តស្វាយរៀង ខេត្តតាកែវ និងខេត្តពោធិ៍សាត់។

សិក្ខាសាលាបណ្តុះបណ្តាលនេះបានបញ្ចប់នៅវេលាម៉ោង ១៧ : ៣០ នាទីរសៀលនាថ្ងៃខែឆ្នាំដដែល ព្រមទាំងមានការចែកជូននៅវិញ្ញាបនប័ត្រជូនសិក្ខាកាមដែលបានចូលរួមវគ្គបណ្តុះបណ្តាលនេះផងដែល ដោយប្រកបដោយភាពស្និតស្នាល និងមានការទទួលខុសត្រូវខ្ពស់។




សិក្ខាសាលា
ស្តីពី
សុវត្ថិភាពឧស្សាហកម្ម
WORKSHOP
ON
INDUSTRIAL SAFETY
General Department of Industry








WORKSHOP
ON
INDUSTRIAL SAFETY


WORKSHOP
ON
INDUSTRIAL SAFETY


សិក្ខាសាលា
ស្តីពី
WORKSHOP
ON
INDUSTRIAL SAFETY
by : Ministry of Industry & Handicraft
of Techniques, Science and Technology
Supply Authority, Phnom Penh 15th November, 2018